# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ...១៧/៣......ក.ស.ភ.

ថ្ងៃ សុក្រ ២កើត ខែបុស្ស ឆ្នាំវក ព.ស ២៥៦០
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ គ.ស ២០១៦

# សេចក្តីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ នៅទីស្នាក់ការកណ្តាល នៃកំពង់ផែស្វយ័តភ្នំពេញ(ក. ស. ភ.) ជិតគល់ស្ពានជ្រោយចង្វារ មានពិធីចុះហត្ថលេខា រវាងកំពង់ផែស្វយ័តភ្នំពេញ និងក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក លើកិច្ចសន្យាស្តីពីការជួលដីទីលានស្តុកសំបកកុងតឺន័រ(ICD) ទំហំ ៩,៣ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ការជួលដីខាងលើ ធ្វើឡើងក្នុងរយៈពេល ៤០ឆ្នាំ(២០១៦-២០៥៦) ឱ្យទៅក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ដើម្បីធ្វើការវិនិយោគសាងសង់មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់(Construction Material Supplies Center "CMSC") ដោយមានសាងសង់ស្តង់សរុបប្រមាណ ៧០០ ស្តង់ ជួលឱ្យទៅអតិថិជនទាំងក្នុងប្រទេស និងក្រៅប្រទេសលក់បោះដុំសម្ភារផ្សេងៗពាក់ព័ន្ធនឹងគ្រឿងសំណង់។

ក. ស. ភ. រំពឹងទុកថានឹងទទួលបាននូវអត្ថប្រយោជន៍ពីគម្រោងសាងសង់មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់(CMSC) នេះ មានជាអាទ៍ះ

- ទទួលបានចំណូលបន្ថែមពីការជួលដី ICD
- បរិមាណកុងតឺន័រឆ្លងកាត់ចំណតផែTS៣ តាមការព្យាករ មានប្រមាណជាង ២០.០០០ (ម្ភៃពាន់)TEUs ក្នុងមួយឆ្នាំៗ ព្រោះថាក្រុមហ៊ុននឹងត្រូវនាំចូលនូវគ្រឿងសំណង់ និងសម្ភារសំណង់ផ្សេងៗទៀតមកពីសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ផ្គត់ផ្គង់ក្នុងគម្រោង
- បង្កើតការងារធ្វើដល់ប្រជាជនកម្ពុជាប្រមាណ ៥.០០០ ការងារបន្ថែមទៀត
- ជំរុញឱ្យជីវភាពរបស់ប្រជាពលរដ្ឋ ដែលរស់នៅជុំវិញតំបន់នោះ កាន់តែល្អប្រសើរ តាមរយៈការប្រកបរបររកស៊ី និងការធ្វើអាជីវកម្មផ្សេងៗ។

សូមជម្រាបជូនថា ក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក គឺជាសាខារបស់ក្រុមហ៊ុន Yunnan Sengmao Investment Co., Ltd. ដែលមានទីស្នាក់ការនៅទីក្រុងគុនមិញ ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។ នៅក្នុងប្រទេសចិន ក្រុមហ៊ុន Yunnan Sengmao Investment Co., Ltd. មានទីផ្សារលក់គ្រឿងសំណង់ឈ្មោះ "Guangfeng New Kunming Food Market", មជ្ឈមណ្ឌល

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិរ:វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៥២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh

លក់គ្រឿងសំណង់ និងក្រុមហ៊ុនផលិតថ្ម និងផ្គត់ផ្គង់ថ្ម។ ជាមួយគ្នានេះ ក្រុមហ៊ុន ក៏មានសាខាមួយទៀត នៅក្នុងប្រទេសឡាវ ដែលធ្វើអាជីវកម្មផ្សារលក់បោះដុំគ្រឿងសំណង់ផងដែរ។

គម្រោងការសាងសង់មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់(CMSC)នេះ នឹងចាប់ផ្តើមដំណើរការចាប់ពីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីចាត់ការកណ្តាល: អគារលេខ ៦៤៩ តិរៈវិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥)២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh